**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

* * * * * *

# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលជួបសំដែងការគួរសម និងពិភាក្សាការងារជាមួយលោកជំទាវ Carmen Moreno ឯកអគ្គរដ្ឋទូតថ្មីនៃសហភាពអឺរ៉ុបប្រចាំកម្ពុជា

នៅព្រឹកថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯក**ឧ**ត្តម **ឧ**បនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យលោកជំទាវ Carmen Moreno ឯកអគ្គរដ្ឋទូតថ្មីនៃសហភាពអឺរ៉ុបប្រចាំកម្ពុជា ចូលជួបសំដែងការគួរសមនិងពិភាក្សាការងារ នៅទីស្តីការក្រសួង។

ជាបឋម **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍ និងអបអរសាទរយ៉ាងកក់ក្តៅចំពោះលោកជំទាវ ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា ហើយសង្ឃឹមយ៉ាងមុតមាំថា យោងលើបទពិសោធន៍ការងាររបស់លោកជំទាវ ទំនាក់ទំនងរវាងកម្ពុជានិងសហភាពអឺរ៉ុប នឹងកាន់តែរឹងមាំបន្ថែមទៀត ។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណដល់សហភាពអឺរ៉ុប ចំពោះការគាំទ្រ និងជំនួយសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់កម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៤ មក ហើយបានបញ្ជាក់ថា ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រៀមសហការការងារជាមួយលោកជំទាវ ដើម្បីរួមចំណែកធ្វើឲ្យបេសកកម្មការទូតរបស់លោកជំទាវនៅកម្ពុជា សម្រេចជោគជ័យ។

ជាការឆ្លើយតប **លោកជំទាវឯកអគ្គរដ្ឋទូត** បានបង្ហាញក្តីរីករាយដែលត្រូវបានតែងតាំងឲ្យមកបំពេញបេសកកម្មការងារនៅកម្ពុជា និងបានសន្យាថា នឹងសហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីពង្រីកភាពជាដៃគូរវាងកម្ពុជា-សហភាពអឺរ៉ុប ក៏ដូចជាបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិទ្វេភាគីដែលមានស្រាប់។ **លោកជំទាវ** ក៏បានថ្លែងការស្ងើចសរសើរចំពោះភាពរីកចម្រើនយ៉ាងឆាប់របស់កម្ពុជា បើប្រៀបធៀបនឹងឆ្នាំ១៩៩៦ ពេលដែលលោកជំទាវអញ្ជើញមកកាន់កម្ពុជាដំបូង។

**លោកជំទាវ** បានកត់សម្គាល់ឃើញថា កម្ពុជាមានវិស័យអាទិភាពជាច្រើនដែលត្រូវអភិវឌ្ឍបន្តទៀត ហើយសហភាពអឺរ៉ុបនឹងពិនិត្យលទ្ធភាពក្នុងការបន្តអនុវត្តកម្មវិធីអភិវឌ្ឍន៍របស់ខ្លួន ឲ្យស្របគ្នាជាមួយនឹងវិស័យអាទិភាពនានា ដែលកម្ពុជាបានដាក់ចេញក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់ខ្លួនសម្រាប់រយៈពេលពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣។ **លោកជំទាវ** ក៏បានសន្យាលើកទឹកចិត្តវិនិយោគិនអឺរ៉ុបមកបណ្តាក់ទុនវិនិយោគកាន់តែច្រើនថែមទៀត ក្នុងវិស័យអាទិភាពទាំងនោះរបស់កម្ពុជា ផងដែរ។



១.

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** និង**លោកជំទាវឯកអគ្គរដ្ឋទូត** ក៏បានផ្លាស់ប្តូរទស្សនៈគ្នាផងដែរ ពាក់ព័ន្ធទៅនឹងឋានៈប្រព័ន្ធអនុគ្រោះពន្ធ "គ្រប់មុខទំនិញ លើកលែងគ្រឿងសព្វាវុធ-EBA"។ ភាគីទាំងពីរបានលើកឡើងថា កិច្ចពិភាក្សារវាងកម្ពុជានិងគណៈកម្មការសហភាពអឺរ៉ុប បានដំណើរការរលូនជាពិសេសតាមរយៈការផ្លាស់ប្តូរទស្សនកិច្ចទៅវិញទៅមក ដោយក្នុងនោះ កម្ពុជាបានទទួលស្វាគមន៍គណៈប្រតិភូស្វែងរកការពិតរបស់គណៈកម្មការសហភាពអឺរ៉ុប ហើយក៏បានបញ្ជូនបេសកជនរបស់កម្ពុជាទៅកាន់សហភាពអឺរ៉ុបផងដែរ ដើម្បីពន្យល់និងបញ្ជាក់ពីសភាពការណ៍ពិតដែលកើតឡើងនៅកម្ពុជា។

លើសពីនេះទៅទៀត **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** និង**លោកជំទាវឯកអគ្គរដ្ឋទូត** ពិភាក្សាលើការត្រៀមរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ នៅកម្ពុជា ឆ្នាំ២០២០ផងដែរ។ លោកជំទាវបានវាយតម្លៃខ្ពស់ចំពោះការត្រៀមរៀបចំរបស់កម្ពុជាថា នឹងប្រព្រឹត្តទៅដោយជោគជ័យ និងបានគូសបញ្ជាក់ថា កិច្ចប្រជុំកំពូលនេះ នឹងផ្តល់ប្រយោជន៍ដល់ទាំងកម្ពុជាដែលជាម្ចាស់ផ្ទះ និងប្រទេសចូលរួមកិច្ចប្រជុំ ជាពិសេសធ្វើឲ្យទំនាក់ទំនងរវាងកម្ពុជា និងប្រទេសចូលរួមទាំងអស់កាន់តែស៊ីជម្រៅឡើង។

ជំនួបពិភាក្សានេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល។

សូមបញ្ជាក់ថា ចាប់តាំងពីឆ្នាំ១៩៩២មក សហភាពអឺរ៉ុបបានផ្តល់មូលនិធិសហប្រតិបត្តិការលើគម្រោងអភិវឌ្ឍន៍ជាច្រើនមកដល់កម្ពុជា ដែលផ្តោតលើវិស័យសង្គមកិច្ច សេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធ អប់រំ សុខាភិបាល និងវិស័យដទៃទៀត ហើយគិតមកត្រឹមឆ្នាំ២០១៥ ជំនួយឥតសំណងរបស់សហភាពអ៊ឺរ៉ុបសម្រាប់កម្ពុជា មានចំនួនសរុបប្រមាណ ៧០០ លានដុល្លារអាមេរិក។ ចំពោះវិស័យទេសចរណ៍វិញ កម្ពុជា បានទទួលភ្ញៀវទេសចរមកពីសហភាពអឺរ៉ុប ប្រមាណជិត៧០ម៉ឺននាក់ នៅឆ្នាំ២០១៨។ ក្រៅពីនេះ ពាណិជ្ជកម្មទ្វេភាគីសម្រេចបានសរុបប្រមាណ ៧,៥ ពាន់លានដុល្លារក្នុងឆ្នាំ២០១៨៕